# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ជូន | ៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | ៖ | ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | ៖ | សហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2019, 14:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អ.ជ.ត.ក៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

---

# សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំកែប្រែទៅលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់សារណាតបទៅនឹងបណ្ដឹងសាទុក្ខ

---

**ដាក់ជូនដោយ៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda J. HOLLIS
(បម្រុង)

**ផ្ញើជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម
ចៅក្រម C. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន៖**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ពេជ អង្គ

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្ដី**
គង់ សំអុន
Anta GUISSÉ

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាស្នើសុំកែប្រែសំណើរបស់ខ្លួនសុំបន្ថែមពេលវេលា និងចំនួនទំព័រដើម្បីដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខ។ សំណើសុំកែប្រែនេះចាំបាច់ណាស់ ដោយសារតែមរណភាពរបស់ នួន ជា និងការបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខរបស់គាត់[1]។ ដូចនេះ សំណើពីដំបូងរបស់សហព្រះរាជអាជ្ញាស្នើសុំយ៉ាងហោចណាស់ ៧០ភាគរយនៃចំនួនទំព័រសរុបរួម និង ៥០ភាគរយនៃពេលវេលារួមដែលផ្តល់ជូន នួន ជា និង ខៀវ សំផន[2] នៅពេលនេះទុកជាមោឃៈ។

2. ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញារក្សាអំណះអំណាងរបស់ខ្លួនថា រយៈពេល ៥ ខែ និង ៣០០ ទំព័រ សម្រាប់លោក ខៀវ សំផន ដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនតែមួយភាសានោះ គឺមានភាពសមស្រប[3]។ ហេតុនេះ ដោយសារតែសហព្រះរាជអាជ្ញានឹងធ្វើការឆ្លើយតបតែទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន នោះ សហព្រះរាជអាជ្ញាស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រ ក្នុងចំនួនដូចគ្នាទៅនឹងការផ្តល់ជូនទៅឲ្យ ខៀវ សំផន ដែរ។ ដូច្នេះ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលទទួលយកអំណះអំណាងរបស់សហព្រះរាជអាជ្ញាថាការបន្ថែមពេលវេលា និងចំនួនទំព័រនៅក្នុងករណីនេះមានភាពសមស្របដែរនោះ សហព្រះរាជអាជ្ញាស្នើសុំរយៈពេល ៥ ខែ និងចំនួន ៣០០ ទំព័រ សម្រាប់សារណាឆ្លើយតបរបស់ខ្លួន តែមួយភាសាជាមុនសិន ដោយដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើបាន និងដោយកំណត់កាលបរិច្ឆេទដាក់សារណាចម្លើយតបនេះយ៉ាងហោចណាស់ ២៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

## II. ប្រវត្តិនីតិវិធី

[1] ឯកសារ **F46/3** សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ (“សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ”)។

[2] ឯកសារ **F47/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំពេលវេលា និងចំនួនទំព័របន្ថែមសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ (“ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា”) កថាខណ្ឌ ២៥។

[3] ឯកសារ **F45/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ (“ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើរបស់ ខៀវ សំផនអំពីសារណាបណ្តឹងសាទុក្ខ”) កថាខណ្ឌ ១៧។

3. សេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២ បានចេញនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨[4]។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមដែលមានសំអាងហេតុពេញលេញរបស់ខ្លួននៅថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៩[5]។

4. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ខៀវ សំផន បានស្នើសុំពេលវេលាសរុបចំនួន ២៤០ ថ្ងៃ និងចំនួនទំព័រសរុប ១០០ ទំព័រ ជាភាសាបារាំង ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[6]។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតបន្ថែមពេលវេលាឲ្យភាគីរយៈពេលពីរខែ និងបង្កើនចំនួនទំព័រពី ៣០ ទំព័រ ទៅដល់ ៦០ ទំព័រ សម្រាប់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[7]។ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[8] ដោយអះអាងថា មានមូលដ្ឋានបណ្តឹងសាទុក្ខចំនួន ១.៨២៤ និងសេចក្តីសម្រេចចំនួន ៣៥៥ ដែលអាចប្តឹងសាទុក្ខបាន[9]។

5. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ខៀវ សំផន បានស្នើសុំពេលវេលាសរុបចំនួន ១០,៥ ខែ និងចំនួនទំព័រសរុប ៩៥០ ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[10]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើនេះនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ដោយផ្អែកលើមូលដ្ឋានថា សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រនេះ មិនធ្លាប់បានធ្វើកន្លងមក និងមិនធ្លាប់ត្រូវបានអនុញ្ញាតទេ[11]។

---

4 សេចក្តីសង្ខេបសាលក្រមសំណុំរឿង ០០២/០២ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (“សេចក្តីសង្ខេបសាលក្រម”)។

5 ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

6 ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ៤២។

7 ឯកសារ **F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១១។

8 ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។

9 ឯកសារ **F45** សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ (“សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន”) កថាខណ្ឌ ៩។

10 ឯកសារ **F45** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៩។

11 ឯកសារ **F45/2** ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាបណ្តឹងសាទុក្ខ។

នៅថ្ងៃដដែលនោះដែរ ខណៈដែលសហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹង ខៀវ សំផន នោះ នួន ជា បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រដោយស្នើសុំពេលវេលាសរុបចំនួន ១០,៥ ខែ និងចំនួនទំព័រសរុប ១.០០០ ទំព័រ សម្រាប់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន[12]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើនេះនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ ដោយផ្អែកលើមូលដ្ឋានថា នួន ជា ខកខានមិនបានផ្ដល់យុត្តិកម្មចំពោះសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រដ៏ច្រើនលើសលុបរបស់ខ្លួន[13]។

6. នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា បានទទួលមរណភាពនៅក្នុងពេលជាប់ឃុំឃាំង[14]។ ហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខប្រឆាំង នួន ជា នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩[15]។

## III. សារណា

7. បន្ទាប់ពីបានពិនិត្យមើលទៅលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន និង នួន ជា[16] សហព្រះរាជអាជ្ញាបានស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាឆ្លើយតបរបស់ខ្លួនយ៉ាងហោចណាស់ ៧០ភាគរយ នៃចំនួនទំព័រសរុបរួម និង

---

12 ឯកសារ **F47** សំណើបន្ទាន់លើកទីមួយរបស់លោក នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ សម្រាប់ដាក់សារណាលើបណ្ដឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ("សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា") កថាខណ្ឌ ១។

13 ឯកសារ **F47/1** ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា។

14 ឯកសារ **F46/1** សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអំពីលិខិតមរណភាពរបស់ នួន ជា ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩។

15 ឯកសារ **F46/3** សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ។

16 ឯកសារ **F45** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន។ ឯកសារ **F47** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា។ ផ្ទុយទៅនឹងការអះអាងរបស់ ខៀវ សំផន សំណើរបស់សហព្រះរាជអាជ្ញាមិនមែនជា "ការប្រែប្រួលមិនឈប់ឈរ" នោះទេ គឺគ្រាន់តែជាសំណើសុំឱ្យមានការពិចារណា ដែលធ្វើឡើងនៅពេលដែលទទួលបានសារណាសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ ខៀវ សំផន និង នួន ជា សូមមើល ឯកសារ **F47/3** ចម្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខ [ឯកសារ F47/1 កថាខណ្ឌ ២៥-២៦(ii)] ("ចម្លើយតបរបស់ ខៀវ សំផន ទៅនឹងសំណើរបស់ ក.ស.ព") កថាខណ្ឌ ៧, ១០-១២,២៣។

៥០ភាគរយ នៃពេលវេលារួមដែលផ្ដល់ជូនទៅក្រុមមេធាវីការពារក្ដី[17] ដោយមានការកំណត់កាលបរិច្ឆេទដាក់សារណាចម្លើយតបនេះតែមួយភាសាជាមុនសិន យ៉ាងហោចណាស់ ៤៥ ថ្ងៃ គិតចាប់ពីពេលជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរនៃសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី[18]។ ដោយសារតែមរណភាពរបស់ នួន ជា និងការរំលត់បណ្ដឹងសាទុក្ខរបស់គាត់[19] សំណើនោះទុកជាមោឃៈ។

8. សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក ចែងឲ្យសារណាតបមានចំនួនទំព័រដូចសារណាបណ្ដឹងសាទុក្ខដែរ[20]។ ចំណុចនេះស្របទៅនឹងវិធានជាធរមាននៅតុលាការអន្តរជាតិ ឬមានលក្ខណៈជាអន្តរជាតិផ្សេងទៀតដែរ[21] ព្រមទាំងការអនុវត្តន៍ជាអន្តរជាតិដែលផ្ដល់ពេលវេលា

---

[17] *សូមមើល* ឯកសារ **F9** សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប កថាខណ្ឌ ១៥។

[18] ឯកសារ **F47/1** ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា កថាខណ្ឌ ២៥។

[19] ឯកសារ **F46/3** សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខ។

[20] សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក ឯកសារ អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨ (ធ្វើវិសោធនកម្មនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១) មាត្រា ៥.២ "ឯកសារដាក់នៅអង្គបុរេជំនុំជម្រះ ឬ អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក មិនត្រូវលើសពី៣០ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ ៦០ទំព័រជាភាសាខ្មែរ លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក សេចក្ដីណែនាំអនុវត្តនេះ ឬ បទបញ្ជាចេញដោយ អ.វ.ត.ក"។

[21] យន្តការបញ្ចប់កិច្ចការដែលនៅសេសសល់ជាអន្តរជាតិសម្រាប់តុលាការអន្តរជាតិ៖ សេចក្ដីណែនាំអនុវត្តស្ដីពីចំនួនទំព័រនៃសារណា និងសំណើសុំ ឯកសារ MICT/11 ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ("សេចក្ដីណែនាំអនុវត្តនៅតុលាការ MICT") កថាខណ្ឌ ៦៖ "សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខពីសាលក្រមចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងមិនត្រូវលើសពី ៣០.០០០ ពាក្យទេ" កថាខណ្ឌ ៧៖ "សារណារបស់អ្នកឆ្លើយតបក្នុងបណ្ដឹងសាទុក្ខពីសាលក្រមស្ដាពររបស់អង្គជំនុំជម្រះសាលាដំបូងមិនត្រូវលើសពី ៣០.០០០ ពាក្យទេ"។ តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ បទបញ្ជារបស់តុលាការ សំណុំរឿង ICC-BD/01-05-16 បទបញ្ជារបស់តុលាការ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ ("សេចក្ដីណែនាំអនុវត្តនៅតុលាការ ICC") បទបញ្ជាលេខ ៥៨(៥)៖ "សារណាបណ្ដឹងសាទុក្ខមិនត្រូវលើសពី ១០០ ទំព័រទេ" បទបញ្ជាលេខ ៥៩(២)៖ "ចម្លើយតបមិនត្រូវលើសពី ១០០ ទំព័រទេ"។ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន៖ សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅអនុការិយាល័យក្រុងឡាអេ (វិសោធនកម្មថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៨) មាត្រា ៦(ង)(i)៖ "សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខប្រឆាំងសាលក្រមផ្ដន្ទាទោសមិនត្រូវលើសពី ១០០ ទំព័រ ឬ ៣០.០០០ ពាក្យទេ ទោះបីសាលក្រមនោះវែងយ៉ាងណាក្ដី" មាត្រា ៦(ង)(ii)៖ "សារណាតបរបស់អ្នកឆ្លើយតបលើបណ្ដឹងសាទុក្ខប្រឆាំងសាលក្រមផ្ដន្ទាទោសមិនត្រូវលើសពី ១០០ ទំព័រ ឬ ៣០.០០០ ពាក្យទេ ទោះបីសាលក្រមនោះវែងយ៉ាងណាក្ដី"។

បន្ថែម និងចំនួនទំព័របន្ថែមសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតបដែលមានជនជាប់ចោទតែម្នាក់ និងមានទំហំស្រដៀងគ្នា[22]។

9. ស្រដៀងគ្នាដែរ ទាក់ទិននឹងការបន្ថែមពេលវេលាវិញ ការអនុវត្តន៍ជាអន្តរជាតិនៅក្នុងសំណុំរឿងដែលមានជនជាប់ចោទតែម្នាក់ និងមានទំហំស្រដៀងគ្នាបង្ហាញថា ទោះបីវិធាននៅតុលាការអន្តរជាតិផ្ដល់ពេលវេលាតិចជាង សម្រាប់ធ្វើសារណាតប[23] ក៏ដោយ តែការផ្ដល់*ពេលវេលាបន្ថែម*សម្រាប់ធ្វើសារណាតបទំនងជាស្មើនឹងពេលវេលាបន្ថែមដែលផ្ដល់ការដាក់សារណាបណ្ដឹងសាទុក្ខដែរ។ ឧទាហរណ៍ ទាំងនៅក្នុង*រឿងក្ដី Mladić* និង*រឿងក្ដី Karadžić* ទោះបីវិធានពាក់ព័ន្ធចែងថាសារណាតបត្រូវដាក់ក្នុងរយៈពេល ៤០ ថ្ងៃ ពុំមែន ៧៥ ថ្ងៃ សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ[24] ក៏ដោយ តែការបន្ថែមពេលវេលាសម្រាប់*ទាំង*សារណាសាទុក្ខ និងសារណាតបមានរយៈពេលដល់ទៅ ៦០ ថ្ងៃ[25]។

---

22 *សូមមើលឧទាហរណ៍ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Mladić* សំណុំរឿង MICT-13-56-A សេចក្ដីសម្រេចលើសំណើរបស់ Ratko Mladić សុំបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ ("សេចក្ដីសម្រេច *Mladić*") ទំព័រ ៤។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿង MICT-13-55-A សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ៣។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba* សេចក្ដីសម្រេចលើសំណើរបស់លោក Bemba សុំបន្ថែមពេលវេលា និងចំនួនពាក្យកំណត់សម្រាប់ដាក់ឯកសារគាំទ្រដល់បណ្ដឹងសាទុក្ខរបស់គាត់ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ កថាខណ្ឌ ១៣-១៤។

23 *សូមមើលឧទាហរណ៍* សេចក្ដីណែនាំអនុវត្តនៅតុលាការ ICC បទបញ្ញាលេខ ៥៨(១)៖ "(…) ម្ចាស់បណ្ដឹងសាទុក្ខត្រូវដាក់សារណាបណ្ដឹងសាទុក្ខក្នុងរយៈពេល ៩០ ថ្ងៃចាប់ពីថ្ងៃទទួលដំណឹងពីសេចក្ដីសម្រេចពាក់ព័ន្ធ" បទបញ្ញាលេខ ៥៩(១) "អ្នកចូលរួមអាចដាក់ចម្លើយតបក្នុងរយៈពេល ៦០ ថ្ងៃពីពេលជូនដំណឹងពីឯកសារគាំទ្របណ្ដឹងសាទុក្ខដូចមានចែងក្នុងបទបញ្ញាលេខ ៥៨ (…)"។

24 ឯកសារ MICT/1/Rev.2 វិធាននីតិវិធី និងភស្ដុតាង (វិសោធនកម្មថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៩) វិធាន ១៣៨៖ "សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខដែលលើកឡើងនូវទឡ្ហីករណ៍ និងឯកសារយោងទាំងអស់ត្រូវដាក់ក្នុងរយៈពេល ៧៥ ថ្ងៃ ចាប់ពីថ្ងៃដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខអនុលោមតាមវិធាន ១៣៣។ (…)" វិធាន ១៣៩៖ "សារណារបស់អ្នកឆ្លើយតបអំពីទឡ្ហីករណ៍ និងឯកសារយោង ត្រូវដាក់ក្នុងរយៈពេល ៤០ ថ្ងៃចាប់ពៅថ្ងៃដាក់សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខ។ (…)"។

25 សេចក្ដីសម្រេច Mladić ទំព័រ ៣-៤។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿង MICT-13-55-A សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ ២។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿង MICT-13-55-A សេចក្ដីសម្រេចលើសំណើថ្មីរបស់អយ្យការសុំបន្ថែមពេលវេលា ដើម្បីដាក់សារណាតប ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ទំព័រ ២-៣។

10. សហព្រះរាជអាជ្ញាលើកឡើងថា ភាពដូចគ្នាទាក់ទិននឹងពេលវេលាបន្ថែម និងចំនួនទំព័របន្ថែម រវាងសារណាបណ្តឹងសាទុក្ខ និងសារណាតបនៅក្នុងសំណុំរឿងនេះ គឺជាការចាំបាច់។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលមានទទ្បីករណ៍បណ្តឹងសាទុក្ខដែលបានចោទប្រកាន់យ៉ាងច្រើនសន្ធឹកសន្ធាប់ខុសពីធម្មតានោះ ពុំទាន់បានផ្តល់ការបញ្ជាក់អំពីបញ្ហាអង្គហេតុ ផ្នែកអង្គច្បាប់ ឬផ្នែកនីតិវិធីដែលលើកយកមកពិភាក្សាឱ្យបានច្បាស់លាស់នៅឡើយទេ[26]។ ហេតុនេះ បើផ្អែកលើចំនួនមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលគាត់បានលើកឡើង និងភាពចាំបាច់នៃចំនួនទំព័រកំណត់ដែលសមហេតុផលនោះ ខៀវ សំផន ហាក់ដូចជានឹងលើកឡើងនូវកំហុសឆ្គងជាច្រើន ដោយមិនបានបង្កើតជាទទ្បីករណ៍គាំទ្រឱ្យបានពេញលេញនោះទេ។ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលទទួលយកមូលដ្ឋានមិនពេញលេញ និងមិនច្បាស់លាស់ ដែលសហព្រះរាជអាជ្ញាយល់ឃើញថា ពុំគួរនឹងទទួលយកទេនោះ សហព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការព្យាយាមបកស្រាយ និងឆ្លើយតបទៅនឹងបញ្ហាអស់ទាំងនេះ ដើម្បីជួយដល់អង្គជំនុំជម្រះ។

11. ហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំពេលវេលាបន្ថែម និងចំនួនទំព័របន្ថែមដូចគ្នាដែរ ទៅនឹងពេលវេលាបន្ថែម និងចំនួនទំព័របន្ថែមដែលអង្គជំនុំជម្រះផ្តល់ឱ្យ ខៀវ សំផន។ ជាងនេះទៀត ឱ្យស្របទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១[27] សហព្រះរាជអាជ្ញាស្នើសុំថា ពេលវេលាកំណត់សម្រាប់ដាក់សារណាតបតែមួយភាសាសិន គួរមានរយៈពេលយ៉ាងហោចណាស់ ២៥ ថ្ងៃ ក្រោយពេលសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ត្រូវបានជូនដំណឹងជាភាសាខ្មែរ[28]។ ចំណុចនេះគឺដើម្បីគោរពតាមលក្ខខណ្ឌតម្រូវរបស់តុលាការដែលត្រូវមានពីរភាសា ព្រមទាំង ដើម្បីអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាជាតិមានពេលវេលាគ្រប់គ្រាន់ ដើម្បី

26 *សូមមើល* ឯកសារ **F45** សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ១៨។

27 អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០២/០១ បានបដិសេធ ទាំង (១) ថា កាលបរិច្ឆេទចុងក្រោយរបស់សហព្រះរាជអាជ្ញាគួរតែចាប់ផ្តើមគិតពីពេលដាក់សំណៅបកប្រែជាភាសាខ្មែរ និង (២) ថា កាលបរិច្ឆេទចុងក្រោយរបស់សហព្រះរាជអាជ្ញាគួរចាប់ផ្តើមគិតពីពេលដាក់តែមួយភាសាសិន។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា កាលបរិច្ឆេទចុងក្រោយរបស់សហព្រះរាជអាជ្ញាគួរមានរយៈពេល ៣០ ថ្ងៃចាប់ពីពេលជូនដំណឹងជាភាសាខ្មែរ ដោយគិតពីសារណាណាមួយដែលត្រូវបានជូនដំណឹងក្រោយគេ។ *សូមមើល* ឯកសារ **F9** សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ២០-២១។

28 សហព្រះរាជអាជ្ញាបានស្នើសុំរយៈពេល ៤៥ ថ្ងៃ ក្រោយពេលសារណារបស់មេធាវីការពារក្តីត្រូវបានជូនដំណឹងជាភាសាខ្មែរ ហើយនៅពេលនេះ បានកែប្រែចំណុចនេះវិញដើម្បីឱ្យស្របទៅនឹងសំណុំរឿងដែលពាក់ព័ន្ធនឹងម្ចាស់បណ្តឹងសាទុក្ខម្នាក់ មិនមែនពីរនាក់ទៀតទេ។

ពិនិត្យលើទឡ្ហីករណ៍របស់ ខៀវ សំផន ជាភាសាខ្មែរ និងដើម្បីធានាថា ជំហរដែលសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិប្រកាន់យក ក្នុងអំឡុងពេលរៀបចំសារណាតបនៅតែមានភាពសម្របសម្រួលដដែល។

## IV. សំណូមពរ

12. អនុលោមតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ សហព្រះរាជអាជ្ញាស្នើសុំដោយគោរពឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តា៖ (១) ផ្តល់ពេលវេលាបន្ថែមសមរម្យឲ្យបាន ៥ ខែ និង បន្ថែមចំនួនទំព័រឲ្យបាន ៣០០ ទំព័រ ដល់ ខៀវ សំផន ដើម្បីដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់តែមួយភាសាជាមុនសិន និង (២) ផ្តល់រយៈពេល ៥ ខែ និង ទំព័រចំនួន ៣០០ ទំព័រ ដល់សហព្រះរាជអាជ្ញាក្នុងការដាក់សារណាតបរបស់ខ្លួនតែមួយភាសាជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ រីឯកាលបរិច្ឆេទកំណត់សម្រាប់ដាក់សារណាតបត្រូវមានរយៈពេល យ៉ាងហោចណាស់ ២៥ ថ្ងៃ ក្រោយពីការជូនដំណឹងអំពីសំណៅបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

សូមលោក-លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៩ខែសីហា ឆ្នាំ២០១៩ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញាជាតិ | រាជធានីភ្នំពេញ | [signature] |
| | លោក William SMITH<br>សហព្រះរាជអាជ្ញារងអន្តរជាតិ<br>ជំនួស<br>លោកស្រី Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង | | [signature] |